01200002

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 02 / 2016
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

D128.1/1/11

# តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២២)

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន** **ប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម ន៉ីយ ថុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦

---

**សាធារណៈ**

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត

---

**សហព្រះរាជអាជ្ញា:**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី មាស មុត:**
អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN- NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២២)

ឯកសារលេខ D128.1/1/11

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត" ("ម្ចាស់បណ្តឹងឧទ្ធរណ៍" និង "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងអំពីបទចោទប្រកាន់") ដែលបានដាក់កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥[1]។

1. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ការស៊ើបអង្កេតតាមផ្លូវតុលាការសម្រាប់សំណុំរឿង ០០៣ ត្រូវបានផ្តួចផ្តើមឡើង ដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ពាក់ព័ន្ធកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់[2]។

2. នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[3]។

3. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ម្ចាស់បណ្តឹងឧទ្ធរណ៍ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ដោយកំបាំងមុខ ("សេចក្តីសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ")[4]។ មាស មុត ត្រូវបានជូនដំណឹងតាមរយៈឧបសម្ព័ន្ធនៃសេចក្តីសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ អំពីការជូនដំណឹងពីបទចោទប្រកាន់ដែលថា គាត់ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩[5]។

---

[1] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D128.1/1/3 ("បណ្តឹងឧទ្ធរណ៍")។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ពាក់ព័ន្ធកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធទីតាំងឧក្រិដ្ឋកម្មទាក់ទងសំណុំរឿង ០០៣ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ D120។

[4] សេចក្តីសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128។

[5] ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ឧបសម្ព័ន្ធនៃសេចក្តីសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128.1។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

4. នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ មាស មុត បានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត[6]។ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងការជូនដំណឹងអំពីបទចោទប្រកាន់ជាភាសាអង់គ្លេស ហើយបន្ទាប់មកជាភាសាខ្មែរនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥[7]។

5. នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួនចំពោះបណ្តឹងឧទ្ធរណ៍[8] ហើយនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះបណ្តឹងឧទ្ធរណ៍[9]។

6. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ មាស មុត បានបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ឯកសារជាភាសាខ្មែរនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរលើការបង្ហាញខ្លួនលើកដំបូង ត្រូវបានដាក់នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ហើយឯកសារជាភាសាអង់គ្លេសត្រូវបានដាក់នៅពេលក្រោយមក ទៅក្នុងសំណុំរឿង នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦[10]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រាប់ដល់ មាស មុត ថា គាត់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[11]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានជូនដំណឹងផងដែរដល់ មាស មុត ថា បទចោទមួយចំនួនដែលបានលើកឡើង

---

[6] សេចក្តីជូនដំណឹងរបស់ មាស មុត អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128.1/1។

[7] បណ្តឹងឧទ្ធរណ៍។

[8] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D128/1/1/7។

[9] ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ឯកសារ D128.1/1/10។

[10] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174។

[11] ដូចជើងទំព័រខាងលើ ទំព័រ ៤ ដល់៨។

នៅក្នុងសេចក្ដីសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ត្រូវបានលុបចោល ដូច្នេះ ហើយ ការចោទប្រកាន់ដែលមាននៅក្នុងសេចក្ដីសម្រេចនេះ លែងមានសុពលភាព[12]។ លើសពីនេះទៀត គាត់បានជូនដំណឹងដល់ មាស មុត ថា ឧក្រិដ្ឋកម្មចំនួនពីរដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា នឹងត្រូវទទួលបានការកំណត់ប្រភេទបទល្មើសបន្ថែមទៀត[13]។

7. នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ម្ចាស់បណ្ដឹងឧទ្ធរណ៍ បានចុះកំណត់ហេតុលើការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំង សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ មាស មុត ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មជាតិ និងអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ[14] ហើយបានដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ មាស មុត ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦[15]។

8. ដោយសារតែការលុបចោលបទចោទមួយចំនួន និងការបន្ថែមការកំណត់ប្រភេទនៃបទល្មើសមួយចំនួនទៅលើអង្គហេតុ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងពេលបង្ហាញខ្លួនលើកដំបូងរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ការជូនដំណឹងអំពីបទចោទ ដែល មាស មុត បានប្ដឹងឧទ្ធរណ៍ លែងជាការពិពណ៌នាត្រឹមត្រូវអំពីបទចោទប្រឆាំងនឹងគាត់ទៀតហើយ។ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ មាស មុត អំពីការផ្លាស់ប្ដូរទាំងនេះ។ ហេតុដូច្នេះ បទចោទប្រកាន់ដែលបានលើកឡើងនៅក្នុងពេលបង្ហាញខ្លួនលើកដំបូងរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺជាបទចោទប្រកាន់ស្ថាពរប្រឆាំងនឹងគាត់នៅពេលនេះ។ ដោយពិចារណាទៅលើចំណុចដែលថា មាស មុត បានដាក់បណ្ដឹងឧទ្ធរណ៍

[12] ដូចជើងទំព័រខាងលើ ទំព័រ ១០។

[13] ដូចជើងទំព័រខាងលើ ទំព័រ ៣។

[14] សេចក្ដីជូនដំណឹងរបស់ មាស មុត អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ មាស មុត ចំពោះការរំលោភបំពារបំពានធ្ងន់ធ្ងរ នៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174/1។

[15] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរ នៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ឯកសារ D174/1/1 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹង របស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

ថ្មី ប្រឆាំងបទចោទដែលត្រូវបានជូនដំណឹងក្នុងពេលបង្ហាញខ្លួនលើកដំបូង ដូច្នេះហើយ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងអំពីបទចោទប្រកាន់ លែងមានសុពលភាពហើយ ហើយគួរត្រូវបានបដិសេធចោល ដោយមិនចាំបាច់ពិចារណាសម្រេចទៅលើភាពអាចទទួលយកបាន ឬអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះឡើយ។

**ហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទះ**

**ច្រានចោល** បណ្តឹងឧទ្ធរណ៍ដោយចាត់ទុកថាគ្មានសុពលភាព។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវប្តឹងតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**